គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រធានគណៈមេធាវី**
មេធាវី លី ចំនួតុលា

**ក្រុមប្រឹក្សាគណៈមេធាវី**
១-មេធាវី កុយ នាម
២-មេធាវី ទេព បុផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ម៉ា ខូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុម ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំនួ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុតា
១៩-មេធាវី ណុប គុណរង្សី
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគ័ន្ធ
២៧-មេធាវី គាន តារា
២៨-មេធាវី ម៉ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា

លេខ ១៨៣/គម/២១

ថ្ងៃ សុក្រ ៨ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០២១

# សេចក្តីអំពាវនាវ
# ស្តីអំពីការចូលជាមេធាវីស្ម័គ្រចិត្ត
# របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដល់សមាជិក-សមាជិកាគណៈមេធាវីទាំងអស់ឱ្យបានជ្រាបថា៖

ដើម្បីចូលរួមចំណែកក្នុងការបំរើវិស័យយុត្តិធមិសង្គមឱ្យកាន់តែប្រសើរឡើង គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយស្តីពីការពិគ្រោះយោបល់ និងការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ។

គោលនយោបាយដែលបានដាក់ចេញនេះ មានទិសដៅជួយផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការពារក្តី ព្រមទាំងតំណាងដោយអាណត្តិ ជូនប្រជាពលរដ្ឋក្រីក្រ រួមទាំងកម្មករនិយោជិកទាំងអស់ ដោយឥតគិតកម្រៃ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជាដើម្បីលើកស្ទួយឧត្តមភាព និងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវីផងដែរ។

ដើម្បីសម្រេចបាននូវគោលនយោបាយនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវការជាចាំបាច់នូវការចូលរួមពីសមាជិក-សមាជិកាមេធាវីទាំងអស់ដោយស្ម័គ្រចិត្តក្នុងដំណើរការលើការពិគ្រោះយោបល់ និងការការពារក្តីជូនប្រជាពលរដ្ឋក្រីក្រ។

តាមរយៈនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការអំពាវនាវដល់សមាជិក-សមាជិកាមេធាវីទាំងអស់ មេត្តាចូលរួមឱ្យបានច្រើន ធ្វើជាមេធាវីស្ម័គ្រចិត្តរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ ក៏ដូចជាការការពារក្តីជូនប្រជាពលរដ្ឋក្រីក្រ និងកម្មករនិយោជិត ដែលខ្វះលទ្ធភាពពឹងពាក់មេធាវី ដើម្បី

ធ្វើការការពារសិទ្ធិរបស់ខ្លួន តាមផ្លូវច្បាប់ ។

ដើម្បីផ្តល់លក្ខណៈងាយស្រួល គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមភ្ជាប់ជូននូវតារាងព័ត៌មានដើម្បីបំពេញនូវឈ្មោះការិយាល័យ ទីតាំង និងពេលវេលាដែលអាចផ្តល់ការពិគ្រោះយោបល់ ព្រមទាំងទីតាំងនៃតុលាការដែលអាចធ្វើជាអ្នកតំណាងដោយអាណត្តិ និងការការពារសិទ្ធិ ព្រមទាំងទូរស័ព្ទទំនាក់ទំនង ។

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា សមាជិក-សមាជិកាគណៈមេធាវីទាំងអស់ នឹងចូលរួមក្នុងកិច្ចការស្ម័គ្រចិត្តដែលប្រកបដោយគុណតម្លៃដ៏ខ្ពស់នេះ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលោកមេធាវី **ទូច ធីរិទ្ធ** ប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ តាមរយៈទូរស័ព្ទលេខ ០៩២ ៤៩៨ ២៨២ ។

សូមសមាជិក-សមាជិកានៃគណៈមេធាវីទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ប្រធាន**

មេធាវី លី-ច័ន្ទតុលា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងព័ត៌មាន

| ល.រ | នាម-គោត្តនាម | ការិយាល័យ | ទីតាំងពិគ្រោះយោបល់ នៅ រាជធានី/ខេត្ត | ថ្ងៃ ពេលវេលា ម៉ោងសម្រាប់ប្រឹក្សាយោបល់ | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃ......................ខែ...........ឆ្នាំ...........ព.ស ២៥៦៤
..................,ថ្ងៃទី............ខែ............ឆ្នាំ...........
ហត្ថលេខា និងត្រាមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងព័ត៌មាន

| ល.រ | នាម-គោត្តនាម | ការិយាល័យ | ចំនួនរឿងដែលទទួលក្នុង ០១ឆ្នាំ | រាជធានី/ខេត្ត នៃការតំណាងដោយអាណត្តិ/ការពារសិទ្ធិ | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃ......................ខែ...........ឆ្នាំ...........ព.ស ២៥៦៤
...................,ថ្ងៃទី.............ខែ............ឆ្នាំ...........
**ហត្ថលេខា និងត្រាមេធាវី**